METHODFINDER



www.MethodFinder.net

# Practitioner's Guide:

## ការវិភាគអំពី សក្តានុពល ភាពទន់ខ្សោយ ឱកាស និង ភាពគំរាមកំហែង

## ( SWOT Analysis)


gtz
Deutsche Gesellschaft für Technische Zusammenarbeit (GTZ) GmbH

Bundesministerium für wirtschaftliche Zusammenarbeit und Entwicklung

Ministry of Land Management, Urban Planning and Construction



Copyright: Royal Government of Cambodia – GTZ supported: Land Administration and Management Project (LMAP)



Concept and Layout: Nikolaus Schall / Michael Becker

# ការវិភាគអំពី សក្តានុពល ភាពទន់ខ្សោយ ឱកាស និង ភាពគំរាមកំហែង ( SWOT Analysis )

## បទអត្ថាធិប្បាយសង្ខេប :



SWOT គឺជាអក្សរកាត់ ដែលអក្សរនីមួយៗតំណាងឱ្យ ( Strengths ) សក្តានុពល ( Weaknesses) ភាពទន់ខ្សោយ (Opportunities) ឱកាស និង (Threats) ភាពគំរាមកំហែង ។ការវិភាគ SWOT អាចយកមកប្រើប្រាស់ ដើម្បីកំណត់និងវិភាគ សក្តានុពល និង ភាពទន់ខ្សោយ របស់គំរោងស្ថាប័ន ឬ គ្រឹះស្ថាន ក៏ដូចជាឱកាស និងភាពគំរាមកំហែង ដែលបានបង្ហាញឱ្យ ឃើញដោយការ ប្រមូលពត៌មាន ទៅលើ បរិស្ថានខាងក្រៅ ។ វាអាចយកមកប្រើប្រាស់ដើម្បីកសាងផែនការ ដែលគិតគូរ ទៅលើកត្តាខាងក្នុង និងខាងក្រៅខុសៗគ្នាមួយចំនួនហើយ ធ្វើឱ្យក្លាយជាអតិបរិមា នូវសក្តានុពលនៃភាពខ្លាំង និងឱកាសដោយកាត់បន្ថយជាអប្បបរិមា នូវភាពទន់ខ្សោយនិង ភាពគំរាមកំហែង ។ បញ្ចប់នៃការវិភាគ SWOT គឺជាមធ្យោបាយនៃ ការទទួលបានពត៌មានពីអ្នកចូលរួមទាំងអស់ ។ ពត៌មានទាំងនោះគឺបានមកពីការអង្កេត និងការវិភាគទៅលើការអង្កេតទាំងនោះដោយអ្នកចូលរួមទាំងអស់ ។




Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## ការវិភាគអំពី សក្តានុពល ភាពទន់ខ្សោយ ឱកាស និង ភាពគំរាមកំហែង ( SWOT Analysis )

### អ្នកដែលអាចប្រើប្រាស់វិធីសាស្រ្តសំខាន់ជាងគេ :

អ្នករៀបចំកសាងផែនការថ្នាក់ស្រុក និងថ្នាក់ខេត្ត និង ភ្នាក់ងារជំនាញជាដៃគូ



### គោលបំណងនៃវិធីនេះ



ការវិភាគ SWOT គឺជារចនាសម្ព័ន្ធសំរាប់វិភាគពីសក្តានុពល ភាពទន់ខ្សោយ ឱកាស និង ភាពគំរាមកំហែង ។ វាត្រូវបានគេអភិវឌ្ឍន៍ក្នុងភាពសាមញ្ញ ក៏ប៉ុន្តែមានប្រសិទ្ធិភាព សំរាប់ការវិភាគនៅក្នុងដំណើរការរៀបចំផែនការយុទ្ធ សាស្រ្តទីផ្សារ ។ ក៏ប៉ុន្តែនៅក្នុងដំណើរការនេះ ការវិភាគ SWOT មិនមែនជាជំហ៊ានដំបូង ឬ ចុងក្រោយបំផុតនោះទេ វាពឹងពាក់អាស្រ័យទៅលើចំណេះដឹងគ្រប់គ្រាន់អំពី បរិស្ថានបច្ចុប្បន្ន និងទំនោរនានា (នៅក្នុងបែបបទនៃការធ្វើ ជំនួញវិញចំនុចទាំងអស់នេះ នឹងទទួលបានការបកស្រាយបញ្ជាក់ដោយការវិភាគទីផ្សារ) ក៏ដូចជាធនធានខាងក្នុងដែរ ។ លើសពីនេះទៀត ក្រៅពីការលំបាកក្នុងការធ្វើអត្ថាធិប្បាយពីបរិស្ថានដោយមិនឱ្យមានភាពច្បាស់លាស់នោះ គ្រប់ផ្នែក ទាំងអស់ដែលពាក់ព័ន្ធ ចាំបាច់ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ជាមុនសិន ។ មុខជំនួញជាធម្មតាតែងតែកំណត់ពីមូល ដ្ឋាននៃបទពិសោធន៍ ពីអតីតកាល ហើយកំណត់ទិសដៅសកម្មភាពទៅតាមនិយមន័យច្បាស់លាស់នៃចំណែកទីផ្សារ និងតំបន់តំរូវការរបស់អតិថិជនក៏ត្រូវតែបំពេញ ។ល ។ នៅក្នុងមុខជំនួញមួយ ចំនួនការយល់ដឹងនេះនឹងយកទៅប្រើក្នុង ការកំណត់នូវទិសដៅបេសកម្មជំនួញក្រៅអំពីទីផ្សារ និងទស្សនទានរបស់អតិថិជន ដែលបានរៀបរាប់រួចមកហើយ នោះនៅក្នុងសមត្ថភាពដែលនឹងត្រូវកសាងនៅក្នុងបទដ្ឋានសង្គម និងបរិដ្ឋានដែលនឹងត្រូវគោរពតាម និងកត្តាដ៏ទៃទៀត ដែលយោលទៅលើអាទិភាពនានានៃការគ្រប់គ្រង និងភាពជាម្ចាស់ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

**ការវិភាគអំពី សក្តានុពល ភាពទន់ខ្សោយ ឱកាស និង ភាពគំរាមកំហែង** ( SWOT Analysis )

## ផលប្រយោជន៍

- ការវិភាគ(SWOT)អាចប្រើប្រាស់សំរាប់:
- ការវិភាគSWOT មានសារៈសំខាន់សំរាប់តែរចនាសម្ព័ន្ធ វិភាគអំពី ការត្រួតពិនិត្យខាងក្នុង និងខាងក្រៅ
- ការវិភាគSWOT ប្រើសំរាប់រៀបចំពតិមានមូលដ្ឋានអំពីគំរោងស្ថាប័ន និងគ្រឹះ ស្ថាន។
- ការវិភាគSWOT សំរួលដល់ការយល់ដឹងទូទៅអំពីការពិត ក្នុងចំណោមទីកន្លែងបំពេញការងារខុសៗគ្នានៅ ក្នុងស្ថាប័នមួយ ឬ រវាងស្ថាប័នច្រើននិងអតិថិជនរបស់ពួកគេ អ្នកផ្គត់ផ្គង់ អ្នកមានបទពិសោធន៍ច្រើន អ្នកមានចំណែកភាគហ៊ុន ឬ ថ្នាក់ដឹកនាំ
- ការវិភាគ SWOT ជួយដល់ការចំរាញ់គំនិតយុទ្ធសាស្ត្រនានា ។
- ការវិភាគSWOTគឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាព និងមានគោលដៅច្បាស់លាស់បំផុតដើម្បីសំរេច ឬ កំណត់ថាតើក្រុម ហ៊ុន ឬ ស្ថាប័នមានសម្ថភាពប៉ុណ្ណេះ នៅពេលដែលគិតគូរពីការប្រឈរមុខនឹងភាពគំរាមកំហែង និងការប្រើប្រាស់នូវឱកាស ដែលមាននោះ ។
- ការវិភាគ SWOT អាចប្រើប្រាស់នៅក្នុងសន្និសិទ្ធ ដែលអ្នកចូលរួមអញ្ជើញមកទីកន្លែង និងស្ថាប័នខុសៗគ្នានោះ។
- ការវិភាគSWOT អាចយកទៅប្រើប្រាស់នៅក្នុងសហគមន៍ ឬស្ថាប័នដែលមានមូលដ្ឋាននៅក្នុងសហគមន៍ ហើយដែលអ្នកចូលរួមការងារពុំទទួលបានប្រាក់ឧបត្ថម្ភ ហើយដែលសមាជិកភាពគឺអាស្រ័យទៅលើទីលំ នៅដ្ឋាន ។
- ការវិភាគ SWOT អាចយកទៅប្រើប្រាស់បាននៅក្នុងស្ថាប័នដូចជាអង្គការ NGO ស្ថាប័នរដ្ឋាភិបាល ឬ ក្រុមហ៊ុនឯកជន ដែលអ្នកចូលរួមគឺជាបុគ្គលិកបៀវត្ស ។

## ដែនកំណត់

- ការវិភាគរឿទជារឿយៗពុំមានតំលៃទេ គឺមិនលើសពីការរៀបចំរចនា សម្ព័ន្ធខ្សោយនោះឡើយ វាមាន លក្ខណៈទូទៅពេក មានលក្ខណៈនៃការអនុវត្តន៍ប្រញាប់ប្រញាល់ពេក ដែលផលិតចេញនូវកត្តាដែលពិបាកនឹងបញ្ជាក់ ពីភាពច្បាស់លាស់មានលក្ខណៈស្រពិចស្រពិល និងមានលំដាប់លំដោយឡើយ ដលចាត់ទុកដោយអ្នកប្រើប្រាស់ឯកជន ថាជាសមាសភាព ដ៏សំខាន់សំរាប់ស្ថានភាពយុទ្ធសាស្ត្ររបស់ស្ថាប័ននានាenaH .

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## ការវិភាគអំពី សក្តានុពល ភាពទន់ខ្សោយ ឱកាស និង ភាពគំរាមកំហែង ( SWOT Analysis )

### ដែនកំណត់



- របៀបដែលការវិភាគឡើឹទធ្វើឡើងជារឿយៗមិនអនុញ្ញាតឱ្យមានការទាក់ទង ការពិភាក្សា និងការបញ្ជាក់ ពីភាពច្បាស់លាស់ធ្វើទៅបានត្រឹមត្រូវទេ នៃកត្តាខាងក្នុង និងខាងក្រៅដែល
  រ ស្មើឡើង ដោយភាគីពាក់ព័ន្ធទាំងអស់នោះ ។
- នៅក្នុងឱកាសទាំងអស់នោះលទ្ធផលទទួលបានពីការវិភាគឡើឹទបង្ហាញលើភាពមិនសូវឱ្យទុកចិត្តបាននៅ ក្នុងការប្រើប្រាស់ក្នុងដំណើរការកសាងយុទ្ធសាស្ត្រ ។
- មានពេលខ្លះ លទ្ធផលទទួលបានពីការវិភាគឡើឹទ នឹងត្រូវបានយកទៅប្រើនៅ ក្នុងដំណើរការកសាងយុទ្ធ សាស្ត្រ ។ប្រសិនបើមានករណីដូច្នេះស្មើដោយភាគីដែលពាក់ព័ន្ធ និងការវិភាគឡើឹទ គុណភាពនៃការចូលរួម នឹងទទួល រងនូវផលវិជ្ជមាន ហើយបានទទួលលទ្ធ ផលទាបជាង ការដែលអាចធ្វើទៅបាននិងចង់បាន ។
- ការវិភាគឡើឹទអាចជាបុព្វហេតុនៃអ្វីដែលបានកំណត់ថាជាការធ្វើឱ្យទៅជាផ្លូវការហួសហេតុពេកនៃដំណើរ ការកសាងយុទ្ធសាស្ត្រ ។
- ក្របខ័ណ្ឌដ៏សាមញ្ញដូចជាការវិភាគឡើឹទ មិនអាចធានាដោយខ្លួនឯង និងបាននូវភាពចាំបាច់ដ៏សំខាន់នៃ ការវិភាគយុទ្ធ សាស្ត្រ ។
- សារពើភណ្ឌនៃការវិភាគឡើឹទ មិនសូវត្រូវបានកែសម្រួលញឹកញាប់ ឡើយសំរាប់ជំរើសគំនិតយុទ្ធសាស្ត្រ ផ្សេងៗនោះ ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## ការវិភាគអំពី សក្តានុពល ភាពទន់ខ្សោយ ឱកាស និង ភាពគំរាមកំហែង ( SWOT Analysis )

### គោលការណ៍និងដំណើរការទូទៅ



ជាជំហ៊ានបឋមសំនួរជាច្រើនត្រូវបានប្រើប្រាស់ដើម្បីណែនាំទីប្រឹក្សានៅក្នុងការសំរេចរបស់ពួកគេ ។

ក-តើអ្វីទៅជាកត្តាដែលនាំឱ្យមុខជំនួញ ឬស្ថាប័នរបស់លោកអ្នកមានដំណើរការបានល ? ហេតុអ្វីបានជាអតិថិ ជនរបស់អ្នកទិញទំនិញពីអ្នក?តើអ្វីដែលបំបែកមុខជំនួញ ឬស្ថាប័នរបស់អ្នកឱ្យខុសពីអ្នកដ៏ទៃទៅនៅក្នុងទីផ្សារ ? តើអ្វីខ្លះ ដែលមានដំណើរការល្អសំរាប់អ្នក ? (សក្តានុពល) ។

ខ-តើអ្វីខ្លះជាមុខជំនួញ ឬស្ថាប័នរបស់អ្នកដែលនាំឱ្យមានការព្រួយបារម្ភ ? តើកត្តាអ្វីខ្លះដែលអ្នកត្រូវតែខិតខំ បំពេញការងារ ? តើអ្វីខ្លះនៅក្នុងមុខ ជំនួញរបស់អ្នកដែលមាន ដំណើរការមិនល្អ ? តើអ្វីខ្លះដែលទាមទារឱ្យមានការកែ លំអរ ? (ភាពទន់ខ្សោយ) ។

គ-តើអ្នកមានឱកាសអ្វីខ្លះដែលអ្នកអាចយកមកប្រើប្រាស់ជាអត្ថប្រយោជន៏នៅក្នុងពេលបច្ចុប្បន្នក៏ដូចជាក្នុង អនាគត ? តើមានទីផ្សារថ្មីៗដែលអាចយកមកប្រើជាមួយនឹងផលិតផលនិងសេវាកម្មបច្ចុប្បន្ន?តើឱកាសអ្វីខ្លះដែល មានសំរាប់កែលំអរវិធីដែលអ្នក បំពេញសកម្មភាពការងារបច្ចុប្បន្នរបស់អ្នកហើយថាតើប្រសិទ្ធិភាពអ្វីខ្លះដែល អ្នកអាចទទួលបាន? តើអ្វីខ្លះទៅជាផលិតផល និងសេវាកម្មថ្មីៗដែលអាចផលិតនិងដាក់បន្ថែមបាន? តើអ្វីខ្លះទៅដែលអ្នកអាចអនុវត្តន៏បានដែលអ្នកពុំទាន់បាន ធ្វើនាពេលនេះ ? (ឱកាស) ។

ឃ-តើមានអ្វីប្រែប្រួលគួរឱ្យកត់សំគាល់នៅក្នុងឧស្សាហកម្ម ដែលអ្នកកំពុងដំណើរការ ? តើកត្តាអ្វីខ្លះជាបញ្ហា ដែលអាចគំរាមកំហែងដល់មុខជំនួញ ឬស្ថាប័នរបស់អ្នក ? តើអ្នកមានគូរប្រកួតប្រជែងឬទេនៅក្នុងទីផ្សាររបស់អ្នក ? (ភាពគំរាមកំហែង) ។

និយមន័យទូលំទូលាយអំពីសក្តានុពល ភាពទន់ខ្សោយ ឱកាស និងភាពគំរាមកំហែងត្រូវបានកំណត់ដើម្បីជា ការណែនាំសំរាប់ការកំណត់របស់ទីប្រឹក្សាគំរោង ។

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## គោលការណ៍និងដំណើរការទូទៅ



**សក្តានុពល ( ភាពខ្លាំង ) :**

ខាងក្នុង ( ដូចជាផ្ទៃក្នុងចំពោះទីប្រឹក្សាគំរោង) ធនធាននានាដែលអាច រាប់បញ្ចូលនូវកត្តា មួយចំនួនដូចជា :

- ការយល់ដឹង
- ការជំរុញលើកទឹកចិត្ត
- បច្ចេកវិជ្ជាជំនាញ
- ទំនាក់ទំនងមុខជំនួញ

សក្តានុពលផ្ទៃក្នុងជួយដល់ការខិតខំប្រើប្រាស់សក្តានុពល និងឱកាសនានា ឬក៏វាជា ទ្រព្យសម្បត្តិឆ្ពោះទៅរកការ លុបបំបាត់នូវភាពគំរាមកំហែង និង អ្វីៗដែលអាចជាការលំបាកនានានោះ ។

**ភាពខ្សោយ :**

គឺជាលក្ខណៈផ្ទៃក្នុងដែលគាំទ្រការកាត់បន្ថយកត្តាដែលប៉ះពាល់ដល់ស្ថានភាពប្រកួតប្រជែងរបស់ទីប្រឹក្សាគំរោង នៅក្នុងឧស្សាហ៍កម្មផ្តល់ទីប្រឹក្សា ឬក៏ភាពទន់ខ្សោយរារាំងដល់ប្រសិទ្ធិភាពនៃការធ្វើអាជីវកម្មនៅលើឱកាសនៃទីផ្សារ បច្ចុប្បន្ន ឬអនាគត ។ ភាពទន់ខ្សោយ អាចរាប់បញ្ចូលនូវកត្តាមួយចំនួនដូចជា :

- ការយល់ដឹងមានកំរិត
- ការមានជំនាញ និងបច្ចេកទេសមិនគ្រប់គ្រាន់
- មានពត៌មានមិនគ្រប់គ្រាន់ទៅលើឱកាសនានា
- មានវប្បធម៌គ្រប់គ្រង និងការរៀបចំកសាងផែនការផ្សេងគ្នា
- មានបទពិសោធន៍តិចតួច

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)

## គោលការណ៍និងដំណើរការនូវនៅ

**ឱកាស :**

គឺជាកត្តាដែលអ្នកទទួលបាននូវភាពមានប្រៀបជាង នៃការប្រកួតប្រជែង ទៅលើអ្នកប្រកបរបរជាទីប្រឹក្សាដ៏ទៃ ទៀត ។ ឱកាស ឬសក្តានុពល គឺជាកត្តាដែលទីប្រឹក្សាចាំបាច់ត្រូវតែរៀនសូត្រដើម្បីប្រើប្រាស់សំរាប់ផលប្រយោជន៏ ផ្ទាល់ខ្លួន ឬសំរាប់ផលប្រយោជន៏របស់ក្រុមហ៊ុន ។ ទោះបីជាឱកាសគឺជា កត្តា ខាងក្រៅ លទ្ធភាពដើម្បីប្រើប្រាស់វាគឺអា ស្រ័យលើលក្ខណៈខាងក្នុងរបស់ទីប្រឹក្សា ។និយាយម្យ៉ាងទៀត គឺទីប្រឹក្សាដែលមានសមត្ថភាពគ្រប់គ្រាន់ល្អអាចប្រើប្រាស់នូវឱកាសដែលមានបាន ។ ឱកាស នានារាប់បញ្ចូលនូវកត្តានានាដូចជា :

- ស្ថានភាពខាងក្រៅដែលអាចអាស្រ័យទាំងស្រុងទៅលើឱកាសដែលផ្តល់ឱ្យ ឬក៏អាចទទួលឥទ្ធិពលមួយផ្នែកពីទីប្រឹក្សាដែលមានការពេញចិត្ត ដល់ការអភិវឌ្ឍន៏ស្ថាប័ន ដែលទាមទារនូវសេវាកម្មរបស់ទីប្រឹក្សា ។
- ទំនោរអាកប្បកិរិយា ឬ លក្ខណៈ និងយុទ្ធសាស្រ្តមានឥទ្ធិពល ទៅលើឱកាសនានាដែលផ្តល់ជូនទីប្រឹក្សា ។

**ភាពគំរាមកំហែង :**

កត្តានានាដែលមិនចាំបាច់មើលឃើញពីខាង អវិជ្ជមានភាពគំរាមកំហែង ក៏អាចជាឧបស័គ្គដែរដែល នាំមក ដោយស្ថានភាពមិនអំណោយផលនៅក្នុងបរិស្ថាន ។ អ្វីដែលសំខាន់នោះគឺភាព គំរាមកំហែងទាមទារនូវទំរង់នៃសកម្ម ភាពដែលបានរៀបចំដែលអាចរាប់ទាំង :

- ស្ថានភាពខាងក្រៅដែលនឹងជះឥទ្ធិពល មិនអំណោយផលទៅលើសមត្ថភាពរបស់ទីប្រឹក្សា ។
- ការប្រែប្រួលនៃដំណើរការឬយុទ្ធសាស្រ្តនានារបស់ស្ថាប័ន ដែលមិនបាន បញ្ជូននៅក្នុងការកាត់បន្ថយថវិការ
  របស់ទីប្រឹក្សាដោយក្រុមហ៊ុនផ្តល់សេវាកម្មទីប្រឹក្សា និងស្ថាប័នមួយចំនួននោះ ។

## References and Sources Used



Jenssen, B.;(ed), **Planning as a Dialogue,** District Development Planning and Management in Developing Countries, SPRING Research Series Nr. 2, Dortmund, 1992

Jenssen, B.; **Towards a Quantification of Agglomeration Disadvantages in Metroploitan Areas of Developing Countries**, University of Dortmund, IRPUD, 1984

Rondinelli, Dennis, A.: **Applied Methods of Regional Planning: The Urban Functions in Rural Development Approach**, Clark University: Rural Marketing Centers Working Group (USAID), 1983a

Thimm, Hr.R., Green, D.A.G., Leupolt, M. (Eds); P**lannning and Operating Rural Centres in Developing Countries,** Studien zur Ländlichen Entwicklung. No. 18, 1986

Copyright: Royal Government of Cambodia – GTZ supported:
Land Administration and Management Project (LMAP)